**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ខុទ្ទកាល័យសម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត
នាយករដ្ឋមន្ត្រី

ក្រុមអ្នកនាំពាក្យ

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# លទ្ធផលជំនួបរវាងសម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងឯកឧត្តម Khalid Ali Abdullah Abel ឯកអគ្គរាជទូតកាតាប្រចាំព្រះរាជាណាចក្រកម្ពុជា

នារសៀល ថ្ងៃទី៧ ខែឧសភា ឆ្នាំ២០២៤ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានអនុញ្ញាតឱ្យ **ឯកឧត្តម** Khalid Ali Abdullah Abel ឯកអគ្គរាជទូតកាតាប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ នៅវិមានសន្តិភាព។

ក្នុងឱកាសនៃជំនួប **ឯកឧត្តម** Khalid Ali Abdullah Abel បានថ្លែងអំណរគុណជូនចំពោះ **សម្តេចធិបតី** ដែលបានឆ្លៀតពេលវេលាដ៏មមាញឹកអនុញ្ញាតឱ្យរូបឯកឧត្តម និងគណៈប្រតិភូ ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ ព្រមទាំងបានពាំនាំនូវការសួរសុខទុក្ខពីឯកឧត្តមនាយករដ្ឋមន្ត្រីកាតា ជូនចំពោះ **សម្តេចធិបតី** និងប្រជាជនកម្ពុជាផងដែរ។ បន្ថែមលើនេះ **ឯកឧត្តមឯកអគ្គរាជទូត** ក៏បានគោរពជម្រាបជូន **សម្តេចធិបតី** ថា ក្នុងអាណត្តិការទូតនៅព្រះរាជាណាចក្រកម្ពុជា **ឯកឧត្តម** ប្តេជ្ញាជំរុញ និងលើកកម្ពស់ទំនាក់ទំនងនៃប្រទេសទាំងពីរឱ្យឈានដល់កម្រិតខ្ពស់បន្ថែមទៀត។ ជាមួយគ្នានេះ **ឯកឧត្តមឯកអគ្គរាជទូត** បានគោរពជម្រាបជូន **សម្តេចធិបតី** អំពីបំណងក្នុងការសម្របសម្រួល និងជំរុញវិនិយោគិនរបស់ប្រទេសកាតាឱ្យមកទស្សនកិច្ចនៅកម្ពុជា ដើម្បីស្វែងរកឱកាសវិនិយោគ និងដៃគូអាជីវកម្ម។

ជាការឆ្លើយតប **សម្តេចធិបតី** បានស្វាគមន៍ចំពោះវត្តមានរបស់ **ឯកឧត្តម** Khalid Ali Abdullah Abel និងគណៈប្រតិភូ ព្រមទាំងបានសម្តែងនូវការអបអរសាទរជូនចំពោះ**ឯកឧត្តម** ដែលត្រូវបានតែងតាំងជាឯកអគ្គរាជទូតប្រចាំព្រះរាជាណាចក្រកម្ពុជា។ **សម្តេចធិបតី** ក៏បានសម្តែងនូវការវាយតម្លៃខ្ពស់ចំពោះការប្តេជ្ញាចិត្តរបស់**ឯកឧត្តមឯកអគ្គរាជទូត**ក្នុងការជំរុញ ក៏ដូចជាពង្រឹង និងពង្រីកទំនាក់ទំនងការទូត និងកិច្ចសហប្រតិបត្តិការរវាងកម្ពុជា-កាតាឱ្យឈានដល់កម្រិតខ្ពស់បន្ថែមទៀត ដោយ **សម្តេចធិបតី** បានគូសបញ្ជាក់ផងថា រាជរដ្ឋាភិបាលកម្ពុជាតែងតែបើកចំហ ស្វាគមន៍ និងគាំទ្រក្នុងការពង្រឹង និងពង្រីកទំនាក់ទំនងរវាងប្រទេសទាំងពីរ។

ខុទ្ទកាល័យ

**សម្ដេចធិបតី** និងឯកឧត្តមឯកអគ្គរាជទូត ក៏បានពិភាក្សា និងឯកភាពគ្នាក្នុងការបន្តជំរុញ និងលើកកម្ពស់នូវទំនាក់ទំនងការទូត ក៏ដូចជាកិច្ចសហប្រតិបត្តិការលើវិស័យសំខាន់ៗ រួមមាន៖ វិស័យពាណិជ្ជកម្ម វិនិយោគ អប់រំ និងការបណ្តុះបណ្តាលវិជ្ជាជីវៈ។

មុននឹងបញ្ចប់ **សម្ដេចធិបតី** បានលើកទឹកចិត្តឱ្យមានជំនួបធុរកិច្ចរវាងបណ្តាក្រុមហ៊ុននៃប្រទេសកាតាជាមួយនឹងក្រសួង-ស្ថាប័នពាក់ព័ន្ធនៅកម្ពុជា និងលើកទឹកចិត្តឱ្យ **ឯកឧត្តមឯកអគ្គរាជទូត** ដើរតួនាទីជាអ្នកសម្របសម្រួល ដើម្បីជាស្ពានផ្សារភ្ជាប់ទំនាក់ទំនងនេះឱ្យកាន់តែប្រសើរឡើង។

ជាទីបញ្ចប់ **សម្ដេចធិបតី** បានជូនពរ **ឯកឧត្តមឯកអគ្គរាជទូត** ឱ្យទទួលបានជោគជ័យជាបន្តបន្ទាប់នៅក្នុងការបំពេញបេសកកម្មការទូតនៅព្រះរាជាណាចក្រកម្ពុជា៕

ថ្ងៃអង្គារ ១៤រោច ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២៤